ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៧ សហវ.អពក

# សេចក្តីជូនដំណឹង

## ស្តីពីការអនុវត្តន៍អាករពិសេសលើសេវាទូរស័ព្ទ

ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម០២៩៧/០៣ ចុះថ្ងៃ ទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ អនុក្រឹត្យលេខ ៧៣ អនក្រ. ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ស្តីពីការកែប្រែអត្រាពន្ធគយ អាករពិសេសលើទំនិញនិងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត អនុក្រឹត្យលេខ២៤អនក្រ.បក ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០៦ ស្តីពីវិសោធនកម្មមាត្រា ៣.ក នៃអនុក្រឹត្យលេខ ៧៣ អនក្រ. ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ស្តីពីការកែប្រែអត្រាពន្ធគយ អាករពិសេសលើទំនិញនិងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់ក្រុមហ៊ុនទាំងអស់ដែលបំរើសេវាកម្មទូរស័ព្ទនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៦ តទៅ សេវាទូរស័ព្ទក្នុងនិងក្រៅប្រទេសត្រូវជាប់អាករពិសេសតាមអត្រា ៣ % ។

ចំពោះក្រុមហ៊ុនទូរស័ព្ទទាំងឡាយណាដែលកន្លងមក បានប្រកាសលើលិខិតប្រកាសសារពើពន្ធអំពីការប្រមូល ឬបានកត់ត្រាក្នុងប្រព័ន្ធវិក្ក័យប័ត្រ នូវអាករពិសេសលើសេវាទូរស័ព្ទតាមអត្រា ១០ % ក្រុមហ៊ុនទាំងនោះត្រូវតែបង់ប្រាក់អាករពិសេសតាមអត្រា ១០ % នេះ ជូននាយកដ្ឋានពន្ធដារឱ្យបានស្រេចបាច់មុនថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៦ ជាកំហិត ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់ថាលោក/លោកស្រីជានាយកក្រុមហ៊ុនទូរស័ព្ទទាំងអស់ ពិតជាយកចិត្តទុកដាក់អនុវត្តត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះ ។ល

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិនា ឆ្នាំ២០០៦

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់